# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកក្កដា និងសម្រាប់រយៈពេល ០៧ខែ ឆ្នាំ២០២០ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារ

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាថ្ងៃព្រហស្បតិ៍ ៩ រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ នៅសាលប្រជុំសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុប លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកក្កដា និងសម្រាប់រយៈពេល ០៧ខែ ឆ្នាំ២០២០ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមរបស់ឯកឧត្តម-លោកជំទាវអគ្គនាយករង លោកប្រធាន-អនុប្រធាននាយកដ្ឋាន សាខាពន្ធដារខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ព្រមទាំងការចូលរួមតាម Video Conference សម្រាប់សាខាពន្ធដារខេត្ត។

ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ ឯកឧត្តម គង់ វិបុល បានបង្ហាញថា ក្នុងខែកក្កដា ឆ្នាំ២០២០ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ របស់អគ្គនាយកដ្ឋាន

ពន្ធដារ) មានចំនួន **៧៨៦,២៤ប៊ីលានរៀល** (ប្រមាណជា **១៩៤,១៣លានដុល្លារអាមេរិក**) ស្មើនឹង **៦,៨១%** នៃផែនការប្រចាំឆ្នាំ បើធៀបនឹងចំណូលពន្ធ-អាករប្រចាំខែកក្កដា ឆ្នាំ២០១៩ ឃើញថាថយចុះចំនួន ៧៥,៧១ប៊ីលានរៀល (ប្រមាណជា ១៦,២២លានដុល្លារអាមេរិក) ស្មើនឹង **៧,៧១%**។

សរុបរយៈពេល ០៧ខែ ឆ្នាំ២០២០ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ របស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន **៧ ៦០៥,៤៦ ប៊ីលានរៀល** (ប្រមាណជា **១ ៨៧៧,៨៩លានដុល្លារអាមេរិក**) ស្មើនឹង **៦៥,៨៩%** នៃផែនការប្រចាំឆ្នាំ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០១៩ ឃើញថាកើនឡើងចំនួន ៦៧០,១១ប៊ីលានរៀល (ប្រមាណជា ១៦៥,៤៦ លានដុល្លារអាមេរិក) ស្មើនឹង **៩,៦០%**។ គួរបញ្ជាក់ផងដែរថា ក្នុងរយៈពេល ០៧ខែ ឆ្នាំ២០២០ ចំណូលពីប្រភេទពន្ធ ០២ នៅរក្សាកំណើនក្នុងនោះ អាករលើតម្លៃបន្ថែមកើនឡើង ៣,១៧% និងពន្ធលើប្រាក់ចំណូលកើនឡើង ២២,៧១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩ ។

សម្រាប់ឆ្នាំ២០២០ នេះ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការអនុវត្តការប្រមូលចំណូលពន្ធបានគ្រប់តាមផែនការច្បាប់ ចំនួនប្រមាណ **១១ ៥៤៣,៣១ ប៊ីលានរៀល** (ប្រមាណ **២ ៨៨៥,៨៣ លានដុល្លារអាមេរិក**) អគ្គនាយកដ្ឋានពន្ធដារនឹងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ថែមទៀត នូវគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ព្រមទាំងដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

- បន្តពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធភាព នូវការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform)



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ និងពង្រឹងការងារចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីធានាការផ្តល់សេវាឱ្យបានល្អប្រសើរ និងការគ្រប់គ្រងចំណូលពន្ធមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធិភាព នូវការសម្រេចរបស់រាជរដ្ឋាភិបាលជុំទី ៥ ស្តីអំពីវិធានការបន្ថែមសម្រួលផ្នែកពន្ធដារ ជួយវិស័យអាកាសចរណ៍និងទេសចរណ៍ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ ១៩ ក្នុងបដិការណ៍នៃការវិបត្តិ និងការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្រោយកូវីដ-១៩
- បន្តពង្រឹងការងារចាត់ចែងលិខិតប្រកាស និងអនុវត្តការគ្រប់គ្រងដាក់លិខិតប្រកាស តាមប្រព័ន្ធអនឡាញ (E-Filing) ព្រមទាំងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ
- ពង្រឹងប្រសិទ្ធិភាពការធ្វើការសវនកម្ម ដោយពន្លឿនរយៈពេលនៃការធ្វើសវនកម្ម និងបន្តបង្កើនកិច្ចសហ-ប្រតិបត្តិការក្នុងការប្រមូលទិន្នន័យពីគ្រប់ប្រភព និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងគោលដៅពង្រឹងអនុលោមភាព



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

សារពើពន្ធ និងការប្រកួតប្រជែងដោយស្មើភាព (Level Playing Field)

- បន្តពង្រឹងប្រសិទ្ធភាពនៃត្រួតពិនិត្យការតាមដានឯកសារ និងផ្តល់លទ្ធភាពជូនអ្នកជាប់ពន្ធ ឬសាធារណជនមានភាពងាយស្រួល ក្នុងការតាមដានពីវឌ្ឍនភាពនៃឯកសាររបស់ខ្លួន ដែលបានដាក់មកកាន់អគ្គនាយកដ្ឋានពន្ធដារ ដោយប្រើប្រាស់នូវកម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (Document Checking and Tracking App)
- ពង្រឹងការអនុវត្តការប្រមូលបំណុលពន្ធ និងវិធានការតឹងទារបំណុលពន្ធ ជាពិសេសបំណុលពន្ធធំៗ ដែលមានសក្តានុពលដោយកំណត់ជាបំណុលអាទិភាព
- បន្តនិងខិតខំពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ដែលជាកត្តាសំខាន់ធ្វើឱ្យប្រសើរឡើងនូវវប្បធម៌ពន្ធដារ ក្នុងនោះមានការ រៀបចំកម្មវិធី "ពន្ធដារកម្ពុជា" ដោយផ្សព្វផ្សាយនិងជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់ (GDT Facebook Live), សេវាឆ្លើយតបតាមប្រពន្ធទូរស័ព្ទ Call Center 1277, កម្មវិធី GDT Live Chat ជាដើម
- បន្តផ្សព្វផ្សាយនិងអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ ២០២០
- បន្តអនុវត្តវិធានការចាំបាច់នានា ដូចមានកំណត់ក្នុងសារាចរណែនាំ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០២០ និងយុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៩-២០២៣។

ជាកិច្ចបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់ នៅតាមអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំប្រឹងប្រែងប្រមូលចំណូល ដែលទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ហើយនេះគឺជាជោគជ័យ និងជាសមិទ្ធផលរួម របស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល។ ជាមួយគ្នានេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក្រើនរម្លឹកនិងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារគ្រប់ជាន់ថ្នាក់ ត្រូវយកចិត្តទុកដាក់ថែទាំសុខភាព និងបង្ការទប់ស្កាត់ចំពោះជម្ងឺផ្លូវដង្ហើមប្រភេទថ្មី Covid-19 និងសូមគោរពជូនពរថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់ជួបតែវិបុលសុខ និងសម្រេចបាននឹងពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ